SPRING PARKS PRIMARY SCHOOL
Learning and Growing - Safety - Together

West Campus - Administration
24 Erica Street, Springvale 3171 ☎ 9546 6402 🖷 9547 2763

Valley Campus
27-39 Clarke Road, Springvale South 3172 ☎ 9547 3222 🖷 9558 4891
✉ spring.parks.ps@education.vic.gov.au springparksps.vic.edu.au





ជំរាបមាតាបិតា/អាណាព្យាបាល

## ថ្ងៃជួបជជែករវាងគ្រូនិងមាតាបិតា:

សូមអរគុណដល់គ្រួសារទាំងឡាយដែលបានមកជួបគ្រូរបស់កុមារនៅថ្ងៃទី៨/៣/២០២៣។ខ្ញុំសង្ឃឹមថាការជួបនេះនឹងផ្តល់ឱកាសឲ្យមាតាបិតាចែករំលែកពត៏មានអំពីកូនលោកអ្នកដល់គ្រូរបស់កុមារ។បើលោកអ្នកពុំបានមកក្នុងថ្ងៃនេះទេ, ហើយប្រាថ្នាមកជួបនៅពេលផ្សេង,សូមទាក់ទងនឹងការិយាល័យហើយសូមតនឹងសារសម្លេង(voice mail)របស់កុមារ។នៅពេលនោះ,គ្រូនឹងទទួលសារតាមរយៈអ៊ីម៉ែលជាមួយនឹង សំណូមពររបស់លោកអ្នក, ឬមាតាបិតាអាចផ្ញើអ៊ីម៉ែលតម្រង់ទៅគ្រូ។

កិច្ចសន្ទនារវាងមាតាបិតានិងគ្រូនៃថ្នាក់ Mr Stroud ត្រូវផ្អាកនៅត្រីមាសសនេះ។ លោកគ្រូនឹងឈប់សំរាកដល់អស់ត្រីមាសនេះហើយត្រឡប់មកសារិញនៅថ្ងៃ ច័ន្ទ ទី២៤/៤។សូមមេត្តាអភ័យទោសដល់គ្រួសារទាំងឡាយចំពោះការរំខាននេះ។

### កំណត់ប្រចាំថ្ងៃ:14/3/2023

១៥/៣: ប្រឡងសាក(NAPLAN)ខាង សរសេរ
១៦/៣: ប្រឡងសាក(NAPLAN) ខាងរៀនអាន
១៧/៣: ប្រឡងសាក(NAPLAN)ខាងប្រើវណ្ណយុតិ
២០/៣: ប្រឡងសាក(NAPLAN)ខាងគណិតសាស្រ្ត
២១/៣: ទិវារួបរួមគ្នានៅសាខាខាងលិច (Harmony Day)
២២/៣: ថ្នាក់ទី៣/៤ធ្វើដំណើរសិក្សានៅក្រៅសាលា
២៣/៣: បាយថ្ងៃត្រង់នឹងសាច់ក្រកអាំង(Hot dog)
២៨/៣: ថ្នាក់ទី១/២ធ្វើដំណើរសិក្សានៅក្រៅសាលា
២៩/៣: ព្រឹត្តិការណ៏សហគមន៏នៅសាខខាងលិច

## ការប្រឡងសាកតាមរយៈអ៊ិនធើណែត(NAPLAN online):

សូមរំឭកថា,ការប្រឡងសាកតាមរយៈអ៊ិនធើណែតនឹងចាប់ផ្តើមពីថ្ងៃទី១៥/៣រហូតដល់ថ្ងៃទី២០/៣សំរាប់ថ្នាក់ទី៣និងទី៥។ការប្រឡងខាងសរ សេរនឹងប្រព្រឹត្តទ្បើងនៅថ្ងៃទី១៥,រៀនអានថ្ងៃទី១៦,របៀបប្រើវណ្ណយុតិថ្ងៃទី១៧,ទីបំផុតគឺគណិតសាស្រ្តនៅថ្ងៃទី២០។ យើងខ្ញុំសង្ឃឹមថាលទ្ធផលនឹងអាចផ្ញើជូនមាតាបិតានៅខែឧសភា។យើងខ្ញុំនឹងផ្ញើទៅផ្ទះជូនភ្លាមប្រសិនជាបានទទួលលទ្ធផលផ្ញើមក។

## ថ្ងៃរួបរួមគ្នា: (Harmony Day)

សាខាវ៉ាល្លីនឹងដើរទៅសាខាខាងលិចដើម្បីចូលរួមសកម្មភាពនៃទិវារួបរួមគ្នានាថ្ងៃអង្គារទី២១/៣,រវាងពីម៉ោង១២:០០និង២:០០។កុមារនឹងត្រឡប់មកសាខារបស់ខ្លួនវិញប្រហែលម៉ោង២:៣០ល្ងាច។ថ្ងៃនេះត្រូវបានទទួលស្គាល់រៀងរាល់ឆ្នាំក្នុងថ្ងៃដូចគ្នា,ហើយនេះជាការអបអរសាទរនៃភាពទីទៃគ្នាហើយរួបរួមប្រជាពលរដ្ឋអូស្រ្តាលីទាំងអស់គ្នាមកពីវប្បធម៏ខុសគ្នា។នេះគឺជាបញ្ហានៃការរួមរស់នឹងគ្នា,ពឹងផ្អែកលើគ្នាសំរាប់យើងទាំងអស់គ្នា។ដើម្បីចូលរួម,អ្នកទាំងអស់គ្នាអាចស្លៀកពាក់ជាពណ៌លឿងទុំឬសម្លៀកបំពាក់ប្រពៃណីយ៏។

## សកម្មភាពសហគមន៏:

នៅថ្ងៃពុធទី២៩/៣,នឹងចាត់ចែងព្រឹត្តិការណ៏សហគមន៏គ្រួសារនៅសាខាខាងលិច។សាលានឹងផ្តល់ជូនគ្រួសារសាច់ក្រកអាំងបរិភោគដោយសេរីមិនគិតថ្លៃមុនព្រឹត្តិការណ៏ចាប់ផ្តើមនៅម៉ោង៤:០០ល្ងាច។

សូមមើលពត៏មានបន្ថែមនៅក្នុងព្រឹត្តិប័ត្រពត៏មាននេះ។

សូមឲ្យពីរសប្តាហ៏ទៅមុខនេះប្រកបដោយក្តីសុខនិងរីករាយ។

Julie Fisher

នាយកសាលា

សាលាយើងមានក្តីសោមនស្សជាគូរភាគីនឹង : Ardoch, IKEA, Woodleigh School, Officeworks and Resilience Project

Anglicare Victoria






# ប្រាក់អំណោយបន្ថែមសំរាប់សន្សំតំម្លៃភ្លើង
# កម្មវិធីទ្រទ្រង់សហគមន

ជួយគាំទ្រតាមរយៈទូរស័ព្ទឬមកជួបផ្ទាល់ចំពោះប្រាក់អំណោយបន្ថែមចំនួន$២៥០ដើម្បីបញ្ចុះថ្លៃភ្លើងតាមរយៈកម្មវិធីប្រាក់រង្វាន់សំរាប់បញ្ចុះថ្លៃភ្លើងនៃកម្មវិធីទ្រទ្រង់សហគមន៏។

**សូមទូរស័ព្ទទៅក្រុម Anglicare Team 1800531741**

## តម្រូវការសិទ្ធិ:

ដើម្បីទទួលប្រាក់$២៥០នេះ,លោកអ្នកត្រូវស្របតាមលក្ខណ្ឌដូចតទៅ:

-ត្រូវជាអ្នកប្រើភ្លើងស្នាក់នៅរដ្ឋវិចតុរីយ៉ា(ឧ:មានគណនី (Electricity account)ប្រើភ្លើង

-ត្រូវជាអ្នកឈរឈ្មោះលើគណនីនេះ(Electricity account)-ផ្ទះមួយទទួលបានតែមួយលើកប៉ុណ្ណោះ

ចំពោះអ្នកដែលមានប័ណ្ណបញ្ចុះថ្លៃ(Concession card)ដែលបានដាក់ប័ណ្ណទទួលប្រាក់$២៥០លើកមុន,ឥឡូវអាចដាក់ពាក្យម្តងទៀតសំរាប់កម្មវិធីដែលបានប្រព្រឹត្តិឡើងនៅថ្ងៃទី១/៧/២០២២។

Scan here to find out more.

## តើទទួលប្រាក់នេះយ៉ាងដូចម្តេច?:

១-រកមើលថាតើលោកអ្នកមានគ្រប់សិទ្ធិឬទេ

២-មានប័ណ្ណបញ្ជាក់បង់ថ្លៃភ្លើង-គណនីធនាគារ (លេខគណនីនិង (BSB)ដើម្បីគេបញ្ចូលប្រាក់$២៥០។

៣-ទាក់ទងនឹង Anglicare Victoria Energy Assistance Program ទូរស័ព្ទលេខ 1800531741 រវាងម៉ោង៨ព្រឹក-៧ល្ងាច) ថ្ងៃច័ន្ទដល់ថ្ងៃសុក្រ,លើកលែងថ្ងៃបុណ្យ។ ឬអ៊ីម៉ែល: energy@anglicarevic.org.au

៤-បើប័ណ្ណសំណូមពរបានអនុម័ត,លោកអ្នកនឹងទទួលបានប្រាក់ចំនួន$២៥០។

anglicarevic.org.au

Interpreter — Translating and Interpreting Services are available

This program is supported by the Victorian State Government

VICTORIA State Government

BETTER TOMORROWS




## St Kilda Football Club





## ផ្ទាក់មូលដ្ឋានធ្វើផ្លែប៉ោមជាខ្សែនៅពេលរៀនវិទ្យាសាស្ត្រក្នុងសប្តាហ៍នេះ





## St Kilda Football Club



## Preps Making Springkle  Sandwiches

ថ្នាក់មូលដ្ឋានរៀនពីសំឡេងនៃព្យញ្ជនៈ S ,

ម៉្លោះហើយយើងខ្ញុំធ្វើសែនវិច។







## ព្រឹត្តិការណ៍សហគមន៍សាលា

### ស្វែងរកអាថ៌កំបាំង



### តើអ្នកណាជាអ្នកលួចនំពីកែវដាក់នំ

យើងត្រូវការជំនួយពីលោកអ្នកដើម្បីដោះស្រាយអាថ៌កំបាំងនេះ !

ពេលល្ងាចដ៏រីករាយនិងដ៏សកម្មសំរាប់គ្រួសារទាំងមូល

កុមាររួមជាក្រុមជាមួយនឹងឱពុកម្តាយរបស់ខ្លួនស្វែងរកតម្រុយនៅទីធ្លាសាលា។

ថ្ងៃពុធ ទី ២៩ ខែ មិនា នៅសាខខាខាងលិច

ពីម៉ោង៣:៣០-៤:០០ល្ងាច- សាច់ក្រករអាំងឥតគិតថ្លៃ

ពីម៉ោង៤:០០-៥:០០ល្ងាច- ល្បែង "តើអ្នកណាជាអ្នកលួចនំក្នុងកែវ "

មានរង្វាន់- លេងសប្បាយ

## STARS OF THE WEEK

### WEST CAMPUS

| Grade | Week 5 | Week 6 |
|---|---|---|
| FA | Kosal / NImrat | Oh mida |
| 1/2 A | Vivaan | Helen |
| 1/2 B | Nirlayp | Jane |
| 3/4 A | Alysha | Mikki |
| 3/4 B | Pharrell | Lyra |
| 5/6 A | Jennifer | Siv Heng |
| 5/6 B | Jayden | Fiona |
| Art | | |
| PE | Cassidy | Alayp |
| Spanish | Oscar & Golden | |

### VALLEY CAMPUS

| Grade | Week 5 | Week 6 |
|---|---|---|
| FA | Jaanvi | Enrique |
| 1/2 L | Alina and Rachael | Ekin |
| 1/2 M | Mandy | Shane |
| 3/4 L | Monika | Aidan |
| 3/4 M | Christina | Ben |
| 5/6 L | Vy | Chloe & Linee |
| 5/6 M | Jason and Tierra | Rosella |
| Art | Bryceson & Ben L | Krustal |
| PE | Amillio & Christina | Ekin |
| Spanish | Aidan & Derrich | |